**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រះវិហារ**

លេខៈ ០៦៩/១៦ -សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១

## អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៦៥០ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តព្រះវិហារ អាណត្តិទី២ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៦/៧៦០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៣/១០៥៩ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ដោយធ្វើសមាហរណកម្មការងារជំរុញចលនាភូមិមួយ ផលិតផលមួយ ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈ អភិបាលស្រុក ។
- យោងប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាក្រុង ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ចរបៀបរបបការងារនៃការិយាល័យទាំងនោះ ។
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣២៤ ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- យោងលិខិតលេខ ០២៩ ភ.១ ផ.១ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

## សម្រេចៈ

**ប្រការ១** ៖ ត្រូវបានបង្កើត " គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ " សរសេរអក្សរកាត់ថា " គ.ខ.ភ១ ផ១ " ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ០១- ឯកឧត្តម | **អ៊ុន ចាន់ដា** | អភិបាលខេត្ត | ប្រធាន |
| ០២- លោក | **គោស៊ុំ ប៊ុនសឿត** | អភិបាលរងខេត្ត | អនុប្រធាន |
| ០៣-លោក | **ខែត យៀង** | តំណាងសភាពាណិជ្ជកម្មខេត្តកំពង់ធំ-ព្រះវិហារ | សមាជិក |
| ០៤- លោក | **មុត តិសិទ្ធនា** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ០៥- លោក | **សេខ សារី** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |

| | | | | |
|---|---|---|---|---|
| ០៦- | លោក | **វ៉ាត់ សោភា** | ប្រធានមន្ទីរព័ត៌មាន | សមាជិក |
| ០៧- | លោក | **ហាន ឆន** | ប្រធានមន្ទីរអប់រំយុវជន និងកីឡា | សមាជិក |
| ០៨- | លោក | **គង់ ទិបុល** | ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ០៩- | លោក | **ពឹង ទ្រីដា** | ប្រធានមន្ទីរកសិកម្ម | សមាជិក |
| ១០- | លោក | **នៅ សុគុណា** | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១- | លោក | **សេង ម៉ុនរឿន** | ប្រធានមន្ទីរផែនការ | សមាជិក |
| ១២- | លោកស្រី | **ម៉ុង សំអុល** | ប្រធានមន្ទីរកិច្ចការនារី | សមាជិក |
| ១៣- | លោក | **អ៊ែ សុខា** | ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១៤- | លោក | **ហ៊ី គា** | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៥- | លោក | **ថោង សារឿន** | ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ១៦- | លោក | **នុត សោភ័ណ្ឌ** | អភិបាលក្រុងព្រះវិហារ | សមាជិក |
| ១៧- | លោក | **អ៊ុង ឌុទ្ធី** | អភិបាលស្រុកត្បែងមានជ័យ | សមាជិក |
| ១៨- | លោក | **ប៉ាង យៀត** | អភិបាលស្រុកគូលែន | សមាជិក |
| ១៩- | លោក | **ជុំ ពុយ** | អភិបាលស្រុកជ័យសែន | សមាជិក |
| ២០- | លោក | **៦ សារ៉ុ** | អភិបាលស្រុករវៀង | សមាជិក |
| ២១- | លោក | **រស់ ហេង** | អភិបាលស្រុកសង្គមថ្មី | សមាជិក |
| ២២- | លោក | **ងា គឹមសេង** | អភិបាលស្រុកជាំក្សាន្ត | សមាជិក |
| ២៣- | លោក | **សុខ សាន្តតារ៉ា** | អភិបាលស្រុកឆែប | សមាជិក |
| ២៤- | លោក | **រស់ ចាន់លី** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | លេខាធិការ |

**ប្រការ២** ៖ គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ មានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ ។
- ជំរុញការអនុវត្តចលនាភូមិ១ ផលិតផល១ឲ្យទទួលបានជោគជ័យ ដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំហានទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ។
- អភិវឌ្ឍន៍ធនធានមនុស្សទាក់ទងនឹងការជំរុញចលនាភូមិ១ ផលិតផល១នៅថ្នាក់ខេត្ត ដើម្បីអនុវត្តចលនាភូមិ១ ផលិតផល១ឲ្យទទួលបានជោគជ័យ រួមចំណែកកាត់បន្ថយភាពក្រីក្រ កាត់បន្ថយចំណាកស្រុក លើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិតរបស់ប្រជាជនសហគមន៍ ។
- ចូលរួម និងដឹកនាំការសិក្សា ស្រាវជ្រាវផលិតផលជាសក្តានុពលនានាដែលមាននៅក្នុងខេត្ត ទាំងផលិត-ផលជាវត្ថុធាតុដើម ផលិតផលកែច្នៃ និងផលិតផលសេវាកម្ម ដើម្បីបញ្ចូលទៅក្នុងចលនាភូមិ១ ផលិតផល១ ដោយធ្វើយ៉ាងណាបន្តអភិវឌ្ឍន៍ផលិតផលទាំងនោះមានលក្ខណៈកាន់តែប្រសើរ កាន់តែពិសេស និងសមស្របតាមទីផ្សារ ទាំងក្នុងសហគមន៍ ក្នុងប្រទេស និងក្រៅប្រទេស ។
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយពីសារៈសំខាន់នៃការជំរុញចលនាភូមិ១ ផលិតផល១ និងលើកទឹកចិត្តប្រជាជននៅតាមមូលដ្ឋានឲ្យចូលរួមគាំទ្រ និងអនុវត្តចលនានេះ ។
- សម្របសម្រួលជាមួយអង្គការ-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានានៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអនុវត្តចលនាភូមិ១ ផលិតផល១ ។
- សម្របសម្រួលរៀបចំអនុវត្តយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីផែនការសកម្មភាពជំរុញចលនាភូមិ១ ផលិតផល១ ។
- រៀបចំបង្កើតសមាគម ឬសហគមន៍គាំទ្រចលនាភូមិ១ ផលិតផល១ ។

- រៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១នៅក្នុងខេត្ត សម្រាប់ធ្វើជាកន្លែងសិក្សាស្រាវជ្រាវ បណ្តុះបណ្តាល ផ្សព្វផ្សាយ ប្រមូលផ្តុំ និងដាក់តាំងបង្ហាញ ឬលក់ផលិតផលភូមិ១ ផលិតផល១ ។

- រៀបចំបង្កើតអនុគណៈកម្មាធិការក្រុង-ស្រុកជំរុញចលនាភូមិ១ ផលិតផល១ ដោយសមាសភាព និងតួនាទីរបស់អនុគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មា-ធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។

- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ និងថ្នាក់ដឹកនាំខេត្ត និងចម្លងជូនមន្ទីរ-ស្ថាប័នពាក់ព័ន្ធ ដើម្បីរួមសហប្រតិបត្តិការក្នុងការជំរុញចលនាភូមិ១ ផលិតផល១ ។

**ប្រការ៣** ៖ ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ( **គ.ខ.ភ១ ផ១** ) មានដូចខាងក្រោម ៖

- គ.ខ.ភ១ ផ១ មានសិទ្ធរៀបចំបែងចែក-ភារកិច្ចទទួលខុសត្រូវលំអិតបន្ថែមទៀតសម្រាប់ជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត និងក្រុង-ស្រុក ។

- គ.ខ.ភ១ ផ១ មានលេខាធិការដ្ឋានមួយដឹកនាំដោយនាយក ឬនាយករងរដ្ឋបាលមួយរូប និងមានជំនួយការមួយចំនួនជាមន្ត្រីរដ្ឋបាលរបស់សាលាខេត្តទៅតាមការចាំបាច់ ដោយមានការឯកភាពពីប្រធានគណៈកម្មាធិការខេត្ត ជំរុញចលនាភូមិ១ ផលិតផល១ ។

- គ.ខ.ភ១ ផ១ អាចអញ្ជើញតំណាងមន្ទីរ-អង្គភាពផ្សេងៗទៀតក្នុងខេត្ត តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ តំណាងវិស័យឯកជន និងតំណាងសហគមន៍ ឬសមាគមចូលរួមប្រជុំផ្តល់យោបល់ ឬពិភាក្សាគ្នាក្នុងការអនុវត្តភារកិច្ចលើកកម្ពស់ចលនាភូមិ១ ផលិតផល១នៅក្នុងខេត្ត ។

- សមាជិក គ.ខ.ភ១ ផ១ ត្រូវចូលរួមប្រជុំរៀងរាល់ ៣ខែម្តង និងករណីពិសេសណាមួយតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ។

- កិច្ចប្រជុំរៀងរាល់ ៣ខែម្តង ឬករណីពិសេសណាមួយ ត្រូវស្ថិតនៅក្រោមអធិបតីភាពប្រធានគណៈកម្មាធិការ ឬអនុប្រធាន ដែលត្រូវបានទទួលការផ្ទេរសិទ្ធពីប្រធានគណៈកម្មាធិការ ។

**ប្រការ៤** ៖ សេចក្តីសម្រេចលេខ ០៤៨ សសរ/គអ/ទអវ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ របស់សាលាខេត្តព្រះវិហារ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** ៖ នាយករដ្ឋបាលសាលាខេត្ត នាយកទីចាត់ការទាំង០៥ និងប្រធានអង្គភាពលទ្ធកម្មចំណុះរចនាសម្ព័ន្ធសាលាខេត្ត ប្រធានមន្ទីរ-អង្គភាពជុំវិញខេត្ត និងឯកឧត្តម អស់លោក លោកស្រីដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

ធ្វើនៅខេត្តព្រះវិហារ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១៦

**អភិបាលខេត្ត**

អ៊ុន_ចាន់ដា

<u>កន្លែងទទួល:</u>
-ក្រសួងមហាផ្ទៃ
-ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ជំរុញចលនាភូមិ១ ផលិតផល១
-ក្រុមប្រឹក្សាខេត្ត
(**ដើម្បីជូនជ្រាប**)
-ដូចក្នុងប្រការ៥
(**ដើម្បីអនុវត្ត**)
-ឯកសារ-កាលប្បវត្តិ